# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ យិន ផាច់ ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហមៈ “យោធា”

## សព្វថ្ងៃរស់នៅភូមិសន្តិភាព ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ផាត កុសល

## ០០ៈ៤៣ៈ៤៤

## ២១ទំព័រ

កុសលៈ អញ្ជើញខ្ញុំសូមណែនាំជាផ្លូវការ ខ្ញុំឈ្មោះថា ផាត កុសល អញ្ជើញបទសម្ភាសឬក៏សេចក្តីស្ទាបស្ទង់មតិនៅក្នុងថ្ងៃនេះគឺសម្រាប់តែធ្វើការអប់រំតែប៉ុណ្ណោះ ហើយនឹងមិនមានបំរើឲ្យគណៈបក្សឬអង្គភាពណាមួយឡើយ ហើយអត្តសញ្ញាណរបស់លោកពូនៅក្នុងថៃនេះ គឺសំរាប់តែធ្វើការអប់រំតែប៉ុណ្ណោះ និងមិនអាចយកទៅបង្ហាយឬក៏យកទៅប្រាប់អ្នកណាទៀត ហើយខ្ញុំសូមថតអានេះដើម្បីឲ្យមានជាលក្ខណៈផ្លូវការណាពូ អញ្ជើញខ្ញុំសូមសម្ភាសលោកនៅក្នុងថ្ងៃនេះ តើបានដែរឬអត់?

ផាច់ៈ សម្ភាសទៅ ។

កុសលៈ អញ្ជើញនៅថ្ងៃនេះ តើជាថ្ងៃទីប៉ុន្មានដែរ?

ផាច់ៈ ថ្ងៃនេះជាថ្ងៃទី៧ ខែកញ្ញា ។

កុសលៈ ហើយភូមិនេះគឺជាភូមិសន្តិភាព?

ផាច់ៈ បាទ ។

កុសលៈ ឃុំត្រពាំងព្រៃឬក៏ប្រជាប្រិយ?

ផាច់ៈ ត្រពាំងព្រៃ ។

កុសលៈ បាទ! តើលោកពូមានឈ្មោះអីដែរបាទ?

ផាច់ៈ ខ្ញុំ ពេញ ផាច់ ។

កុសលៈ តើមានឈ្មោះអីផ្សេងដែលទេលោកពូ?

ផាច់ៈ ទេ មានឈ្មោះតែមួយនេះទេ ។

កុសលៈ ផាចសរសេរអញ្ជើង តើត្រូវដែរទេ?

ផាច់ៈ ត្រូវហើយ ។

កុសលៈ តើលោកតាចាំថ្ងៃខែកំណើតដែលឬទេ?

ដាច់ៈ ចាំតើ នៅថ្ងៃ១ខែ១ ឆ្នាំ៥៦ ។

កុសលៈ ភូមិកំណើតលោកតានៅឯណាដែរ?

ដាច់ៈ ភូមិកំណើតខ្ញុំនៅភូមិ គោកទើង ។

កុសលៈ សរសេរម៉េចដែរតា?

ដាច់ៈ គោកទើង ។

កុសលៈ សរសេរដូចតាំងគោកយើងនេះ ហើយឃុំអីដែរ?

ដាច់ៈ ឃុំចាន់សរ ស្រុកសូទ្រនិគម ។

កុសលៈ អញ្ចឹងអ្នកសៀមរាបដូចតែគ្នាហ្នឹង មិនជាឆ្ងាយពីគ្នាប៉ុន្មានទេ តើលោកតាមានចាំថាមានអ្វីខ្លះកើតឡើងនៅមុនឆ្នាំ៧៥ តើមានរឿងអ្វីខ្លះដែលលោកតានៅចាំ ទាក់ទងទៅនឹងគ្រួសារលោកតា ទីមួយទាក់ទងទៅនឹងសម្តេចសីហនុដែលគេធ្វើរដ្ឋប្រហារទំលាក់គាត់ តើលោកតាមាននៅចាំព្រឹត្តិការណ៍នឹងដែលទេ?

ដាច់ៈ ព្រោះនៅពេលនោះនៅផ្ទះ មិនបានចាំទេ ព្រោះថាអារឿងដែលយើងធ្វើជាទ័ពនេះមិនបានដឹងរឿងជ្រួតជ្រាបអីនឹងគេទេ ពីព្រោះខ្ញុំនៅផ្ទះ នៅតាមផ្ទះនៅតាមស្រុក អញ្ចឹងប្រជាពលរដ្ឋអីមិនសូវបានដឹងរឿងអីប៉ុន្មានទេ ។

កុសលៈ អញ្ចឹងនៅពេលនោះ តើលោកតានៅរៀននៅឡើយទេ?

ដាច់ៈ អត់ទេ ឈប់រៀនហើយ ។

កុសលៈ អញ្ចឹងនៅឆ្នាំ៧០ឈប់រៀនហើយ?

ដាច់ៈ ឆ្នាំ៧០ឈប់រៀនហើយ ហើយមនុស្សចេះតែរត់ទៅនេះនោះអញ្ចឹងទៅ ហើយមនុស្សនៅដើរឃ្វាលគោរក្របីនៅឡើយហ្នឹង កាលនោះនៅក្មេងដែរហ្នឹងពេលនោះ ។

កុសលៈ តើលោកតាមានបងប្អូនប៉ុន្មាននាក់ដែរលោកតា?

ដាច់ៈ ខ្ញុំមាន៦នាក់ ។

កុសលៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរ?

ដាច់ៈ ប្រុស៥ ស្រី១ ។

កុសលៈ ទាំងអស់ចូលទាហានទាំងអស់ហ្ន៎ ប្រុសទាំង៥នាក់ហ្នឹង?

ដាច់ៈ ចូលអី?

កុសលៈ ចូលទៅបក្សជិវត្តន៍ទាំងអស់?

ដាច់៖ អត់ទេ បងប្អូនខ្ញុំដូចជាអត់មានឃើញចូលទៅម៉ាក់មួយទេ គឺមានចូលតែខ្ញុំទេនៅឆ្នាំ៨០ជាង នេះ ។

កុសល៖ អញ្ចឹងមុខរបរឪពុកម្ដាយលោកធ្វើអ្វីដែរ?

ដាច់៖ ធ្វើស្រែ ។

កុសល៖ តើនៅពេលនោះ បើគិតពីគ្រួសារលោកពូ តើមានឬក្រ ឬមធ្យម?

ដាច់៖ ដូចជាក្រដែរហ្នឹង ពីព្រោះថានៅធ្វើស្រែ ។

កុសល៖ ចុះសាសនា លោកពូកាន់អីដែរ?

ដាច់៖ ព្រះពុទ្ធ ។

កុសល៖ ខ្ញុំសួរនេះ ពីព្រោះថាមានអ្នកខ្លះទៅគេកាន់សាសនា អ៊ីស្លាមអីដែរ?

ដាច់៖ វាអញ្ចឹងហើយ ពីព្រោះថាមានអ្នកខ្លះគេកាន់យេស៊ូអញ្ចឹងដែរ ។

កុសល៖ ពីព្រោះថាទំនាមទំលាប់យើងជាខ្មែរ គឺថាខ្មែរ?

ដាច់៖ ខ្មែរគឺល្អ ។

កុសល៖ អញ្ចឹងនៅពេលនោះគឺលោកពូមិនទាន់រៀបការទេ តើលោកពូនៅពេលនោះមានអាយុប៉ុន្មានឆ្នាំ នៅពេលដែលគេរំដោះឆ្នាំ៧៥?

ដាច់៖ គិតទៅវា....ប៉ុន្មានឆ្នាំទេ ១០ប៉ុន្មានទេ ។

កុសល៖ តើលោកពូចូលទៅបក្សជិវត្តន៍នៅឆ្នាំណា?

ដាច់៖ ទេ! ទើបតែចូល៨០ប៉ុន្មាននេះទេ ។

កុសល៖ ចូលតាំងពីឆ្នាំ៧០មក?

ដាច់៖ ទេ! ទើបតែចូលមកក្រោយនេះទេ នៅឆ្នាំ៨៧នេះទេ នៅក្រោយទេ អញ្ចឹងបានជាខ្ញុំអត់សូវដឹងរឿងប្រវត្តិអីនឹងគេទេ ។

កុសល៖ អញ្ចឹងបានន័យថានៅពេលសម័យរដ្ឋកម្ពុជាហ្នឹង លោកពូនៅស្រុកនៅឡើយទេ?

ដាច់៖ បាទ! នៅស្រុកកំណើតនៅឡើយទេ ដល់ទេក្រោយមកទៀតគេធ្វើសមារន្និកម្មមក ខ្ញុំប្រុចមកនេះ ។

កុសល៖ ចុះពីនៅក្នុងឆ្នាំ៧៥-៧៩ តើលោកពូនៅឯណាដែរ?

ដាច់៖ ខ្ញុំពី៧៥-៧៩នៅផ្ទះ នៅសូទ្រនិគម នៅភូមិគោកទើង ។

កុសល៖ តើនៅពេលមានការរំដោះនៅឆ្នាំ៧៥ហ្នឹង តើមានការប្រែប្រួលនៅក្នុងភូមិយ៉ាងម៉េចដែរ នៅក្នុងភូមិ ?

ដាច់៖ កាលនោះ នៅតូចដែរហ្នឹង គិតថាវានៅជាធាតុកុមារណា អញ្ចឹងឲ្យថាវាមានលក្ខណៈឲ្យពេញនិងការងារគឺថាអត់ទេ ហើយការអប់រំរបស់គេនៅជំនាន់នោះក៏យើងអត់យល់ដែរ ពីព្រោះថាយើងនៅកុមារនៅពេលនោះ គឺយើងអត់មានជ្រួតជ្រាបអីទេ យើងម្យ៉ាងសភាពប្រជាពលរដ្ឋនៅពេលនោះ គឺមានសភាពក្រីក្រច្រើនណា អញ្ចឹងការយល់ដឹងគឺនៅមានកំរិត គឺថានៅតិចណាស់ ។

កុសលៈ នៅពេលនោះលោកពូមានអាយុប្រហែលជា២០ឆ្នាំហើយមើលទៅ?

ដាច់៖ អត់ដល់ទេ ។

កុសលៈ តែគេមានបង្កើតសហករណ៍អីដែលទេ?

ដាច់៖ គេមានហើយ បង្កើតសហករណ៍ហើយនៅពេលនោះ ប៉ុននៅកាលណោះគឺខ្ញុំនៅជាកុមារវានៅតូច ។

កុសលៈ តែពេលនោះពូមានអាយុប្រហែលជា២០ឆ្នាំហើយ ពីព្រោះថាពូកើតនៅឆ្នាំ៥៦ បើដល់ឆ្នាំ៧៦គឺលោកពមានអាយុ២០ឆ្នាំហើយ?

ដាច់៖ ៦៧គឺខ្ញុំនៅតែនឹងផ្ទះទេ ។

កុសលៈ ហើយនៅក្នុងសហករណ៍នោះ តើគេឲ្យលោកពូទៅលើកដីទៅរែកអីដែលទេ?

ដាច់៖ ទៅលើកទំនប់នោះណា កាលនោះគឺនៅជាប្រធានកុមារ អញ្ចឹងគេឲ្យទៅលើកទំនប់ ជីកប្រលាយនោះណា ។

កុសលៈ តើលោកពូមាននៅចាំដែលទេ ថាគេឲ្យលោកពូទៅជីកនៅឯណាខ្លះ?

ដាច់៖ នៅភ្នំគូលែនយើងនេះ អន្គធំនេះ ។

កុសលៈ គេធ្វើជាប្រពន្ធ័ធារាសាស្រ្តអីយ៉ាងម៉េចៗដែរ?

ដាច់៖ ទំនប់នោះប្រណាប់ដែរណា ។

កុសលៈ ទមនប់នោះឈ្មោះថាទនប់ភ្នំគូលែន?

ដាច់៖ ទំនប់ព្រះអន្គធំ គេហៅថាព្រះអន្គធំនៅលើភ្នំគូលែននោះ ។

កុសលៈ លោកពូឃើញព្រិត្តិការណ៍នៅពេលនោះ តើមានមនុស្សច្រើនដែលទេ?

ដាច់៖ ទេច្រើន ប្រហែលប៉ុន្មានរយនាក់ ។

កុសលៈ ប្រហែលជា៤០០-៥០០នាក់ទេ?

ដាច់៖ ប្រហែល៥០០-៦០០នាក់អត់បាត់ទេ ។

កុសលៈ អញ្ចឹងទំនប់នោះធំមែនទែន ពីព្រោះមានមនុស្សធ្វើការច្រើន?

ដាច់៖ បា៎! ទំនប់នោះការដ្ឋានធំណា ពីព្រោះថាទឹកឈូឡាប់ហើយ ។

កុសលៈ ហើយចុះការហូបចុកអីយ៉ាងម៉េចដែរ?

ដាចៈ អញ្ចុះហើយនៅជំនាន់នោះ អញ្ចឹងគឺថាដូចតែលោកក្មួយឯងថាហើយ គឺថាឪពុកម្ដាយលោកក្មួយឯងយ៉ាងម៉េច គឺខ្ញុំអញ្ចុះហើយគឺថាដូចតែគ្នាទេ គឺថាដូចតែគ្នាទេ ប្រវត្តិនៅពេលនោះគឺថាម៉ែឪក្មួយឯងប្អូនឯងយ៉ាងម៉េច គឺថាខ្ញុំដូចតែគ្នាដែរ របប៣ឆ្នាំ៨ខែ២០ថ្ងៃនោះ ។

កុសលៈ ហើយកុមារគេឲ្យទៅធ្វើអីខ្លះទៅ?

ដាច់ៈ បើគិតថា វារាងទ្រើសបន្តិចទៅ គឺទៅតាមអាយុវាទៅណា បើថារាងទ្រើសបន្តិចទៅគឺគេឲ្យជិញ្ជាំដីដាក់ស្រែអញ្ចឹងទៅ គឺថាគេមានក្រុមមានកងគេអញ្ចឹងទៅណា អាតូចក៏មានដែរ ហើយអាទ្រើសបន្តិចទៅ គឺគេឲ្យធ្វើការរាងធ្ងន់បន្តិចទៅ និយាយទៅគឺគេគិតតាមវ័យណា គឺថាតាមធំតាមតូច គឺនៅពេលនោះ ហ៉ើយការហូបចុកនៅពេលនោះគឺថាវាដោយតំបន់ទេ ដោយកន្លែងទេ លឺថានៅកន្លែងខ្លះគេបន្តក់បាយបន្តក់ទឹក កន្លែងខ្លះគេនិយាយអញ្ចឹង បើថាកន្លែងខ្ញុំសហករណ៍ភូមិខ្ញុំចាន់សនេះគឺថា ពីព្រោះថាកន្លែងខ្ញុំនេះគឺជាសហករណ៍មួយដែលគេហៅថាបន្ទុះបណ្ដាលអញ្ចឹងណា ដល់អញ្ចឹងទៅគឺថាគេមិនសូវជាគាបទេ ។

កុសលៈ គេបន្ទុះបណ្ដាលឲ្យទៅជាប្រជាជនបក្សជិវត្តន៍ឬក៏យ៉ាងម៉េច?

ដាច់ៈ ទៅជាប្រជាជនគំរូ ដែលនៅក្នុងពេល៣ឆ្នាំ៨ខែ២០ថ្ងៃនោះណា ។

កុសលៈ ដោយលោកពូជាប្រធានកុមារ តើគេអាសារហៅពូទៅនៃណាំទៅរៀនសូត្រអីដែលទេ?

ដាច់ៈ ខ្លាំងគឺហៅប្រជុំត្រឹមតែថ្នាក់ក្រោម ដូចថានៅបន្ទាប់យើងនេះ មិនដែលដែលបានទៅដល់អាធំអីទេ អាកំពលអីទេ ។

កុសលៈ ហើយចុះពួកកំពូលមានដែលចុះមកដែលទេ តើលោកពូមានដែលស្គាល់មេកំពូលដែរទេ?

ដាច់ៈ មិនដឹងជាអាកំពូលអីនោះនៅឯណាអីទេ លឺតែគេថាតាមទស្សនាវដ្ដីអីគេនោះឯង ។

កុសលៈ តាមរយៈទង់បក្សជិវត្តន៍អីនោះ?

ដាច់ៈ នោះហែង

កុសលៈ ចុះលោកពូមានដែលស្គាល់អ្នកធំណាដែលទេ?

ដាច់ៈ អត់ដែលស្គាល់ទេ តែដល់តែក្រោយមកលឺគេថាមេខ្មែរក្រហមគឺតា ប៉ុល ពត អីបណ្ដោយទៅ ប៉ុល ពត អៀង សារី ខៀវ សំផន គឺថាលឺតាមអាដែងនេះណា អាតាមវិទ្យុតាមរយៈដែលគេចាក់ផ្សាយនៅសម័យកម្ពុជានោះណា ។

កុសលៈ តែនៅជំនាន់នោះគឺអត់ដែលបានស្គាល់សោះ?

ដាច់ៈ ពេលនោះគឺគ្មានដែលលឺទេ ។

កុសលៈ ហើយនៅក្នុងមួយក្រុមកុមាររបស់លោកពូមានប៉ុន្មាននាក់ដែរទៅ?

ដាច់៖ មាន១២ ។

កុសល៖ ហើយនៅពេលក្រោយមក មាននៅរស់ដែលទេ?

ដាច់៖ ក្រោយមកគេធំអញ្ចឹងទៅ ហើយខ្ញុំបានគ្រួសារមករស់នៅក្នុងភូមិអញ្ចឹងទៅ ហើយខ្លះក៏គេទៅចូលទ័ពអីខ្លះអញ្ចឹងទៅណា នៅក្នុងមួយក្រុមពីដើមនោះណា គឺថាបែកបាក់គ្នាអស់ហើយ ខ្លះគេបានប្រពន្ធទៅរស់នៅនេះនៅនោះអស់ទៅ ទាំង១២នាក់ ។

កុសល៖ ចុះក្រោយមកទៀតនៅពេលដែលវៀតណាមគេលុកលុយចូលស្រុកយើងនេះ តើលោកពូរស់នៅឯណាដែរ?

ដាច់៖ ខ្ញុំនៅឯស្រុក ។

កុសល៖ ចេះតែនៅនឹងទៅ អត់មានការភ័យខ្លាចអីទេ?

ដាច់៖ អត់មានភ័យអីទេ តែដូចថាមួយរឹបនោះគឺថាយើងនៅខាងនោះហើយណា ដល់ទេពេលដែលរដ្ឋកម្ពុជាខាង ហ៊ុន សែន នេះគាត់ដាក់រឹបអញ្ចឹងមក ពួកខ្មែរក្រហមដល់អញ្ចឹងគឺវារត់ចេញបណ្តោយ គឺវារត់ចេញមក ហើយលឺគេថាវានៅម៉ុំយើងនៅតាមដងភ្នំនេះ ដល់តែពេលក្រោយមកទៀត ហ៊ុន សែន គាត់ចេះតែបង្រួបបង្រួមទៅ ខាងនេះគេត្រូវចូលយើងនៅឆ្នាំ៩៨នេះ ដល់អញ្ចឹងលឺគេថាបង្រួមបង្រួមអស់ហើយ គឺនៅចុងឆ្នាំ៩៨នេះក៏ត្រឡប់មកនៅនេះឯង ចុះផ្ទះខ្ញុំមុនដំបូងនៅត្រង់ណោះ ដល់ពេលដែលខ្ញុំមកហើយគេរៀបចំនៅថ្មីក៏នៅផ្លូវនេះឯង ផ្ទះខ្ញុំធ្វើនៅត្រង់នេះឯង មុនដំបូងគឺអត់មានផ្លូវទេ គឺសុទ្ធតែព្រៃស្បូវ ។

កុសល៖ អញ្ចឹងនៅក្នុងរបបពាឆ្នាំ៧ខែ២០ថ្ងៃនេះ តើលោកពូមានដែលភ័យខ្លាចថាមានការបាត់បង់ជីវិតខ្លួនឯង បក៏ក្រុមគ្រួសារលោកពូដែលអត់?

ដាច់៖ បាទ! គ្រួសារខ្ញុំអត់មានបាត់អីផង ។

កុសល៖ តែមានការភ័យខ្លាចអីដែលអត់?

ដាច់៖ ដូចថាអត់មានគ្រួសារខ្លួនឯងនេះ គឺអញ្ចឹងគឺថាវាមិនជាសូវភ័យណា ពីព្រោះថាគ្រួសារខ្លួនឯងវាមិនដែលមានបញ្ហា ដូចថាមិនដែលឃើញគេចាប់យកទៅវៃចោលអីណា គ្រួសារខ្ញុំហើយម្តាយឪពុកខ្ញុំក៏អត់ទេ គឺគាត់ស្លាប់ដោយសារតែជំងឺដែលទេ គឺថាគាត់ចាស់ហើយគាត់ក៏ខូចទៅ ។

កុសល៖ ហើយចុះគេមានដែលធ្វើបាបអីដែលទេ?

ដាច់៖ ទេគ្រួសារខ្ញុំគេមិនដែលធ្វើទារុណកម្មអីទេ អានេះគឺនិយាយតែពីគ្រួសារខ្ញុំមួយណា បើគេឯងអីអានោះគឺខ្ញុំមិនដឹងទេ ។

កុសល៖ ហើយចុះដូចថានៅក្នុងការដ្ឋានអី តើលោកពូមានដែលឃើញគេចាប់អីយកទៅដែលទេ?

ដាច់៖ គឺឃើញគេចាប់យកទៅខ្លះដែលនឹងណា តែគ្រាន់ថាមិនដឹងជាគេយកទៅឯណា ។

កុសលៈ ហើយក៏បាត់រហូតទៅ?

ដាច់៖ ខ្លះក៏មិនដែលឃើញមកវិញដែលណា ហ៊ឺ....ហ៊ឺ អ្នកខ្លះនោះគឺអត់ឃើញទេ ។

កុសលៈ លោកពូមានដែលឃើញអ្នកជំងឺអីគេស្លាប់នៅក្នុងការដ្ឋានអីដែលទេ តើលោកពូមានដែលឃើញដែលទេ?

ដាច់៖ ទេ! ឃើញតែគេយកទៅពេទ្យនៅកន្លែងចាន់សនោះ គឺគេយកទៅពេទ្យនោះទៅ គឺមិនដែលឃើញស្លាប់នៅកន្លែងធ្វើពលកម្មនេះទេ បើនិយាយពីកន្លែងធ្វើពលកម្មលើកទំនប់លើកប្រលាយអី គឺមិនដែលឃើញមានបញ្ហាអីទេ មិនដែលឃើញមានមនុស្សងាប់អីនៅទីនោះទេ ប៉ុន្តែបើថាឈឺនោះគឺមានឈឺមែន ដល់ពេលឈឺគឺគេបញ្ជូនទៅកន្លែងពេទ្យគេអីអញ្ចឹងទៅណា គឺថាផុតអស់ទៅ ។

កុសលៈ ចុះនៅពេលដែលលោកពូត្រឡប់មកដល់ភូមិស្រុកវិញ ពូមានដែលឃើញអ្នកភូមិស្រុកអីមានបាត់បង់បួនអីច្រើនដែលទេ?

ដាច់៖ គឺមាន តែមិនដែលបានសួរអីគេអារឿងអញ្ចឹងទេ តែគ្រាន់តែលឺគេថាកូនអញវាស្លាប់ កូនអញវាបាត់អីអញ្ចេះចុះទៅណា តែយើងមិនដែលបានទៅតាមដានអីរឿងអញ្ចេះអីជងនោះទេ ពីព្រោះគិតនៅពេលនោះគឺគិតជីវិតមនុស្សអាត្មាម្នាក់ៗដែរ គឺថាគ្រួសារបួនឯងក៏អញ្ចឹងហើយគ្រួសារខ្ញុំក៏អញ្ចឹង គឺថាយើងធ្វើម៉េចកុំឲ្យតែយើងធ្វើខុស គឺថាកុំឲ្យវាយកទោសយកប៉ឺអី ហើយក៏មិនដែលមានការភ័យភិតអីទេ ពីព្រោះវាមិនដែលបានធ្វើខុសអី មិនដែលមានបានគេចាប់គេចងអី អានេះគ្រួសារខ្ញុំទេណា ។

កុសលៈ អញ្ចឹងបញ្ជាក់ថានៅក្នុងរបបនោះ គឺលោកពូមិនដែលបានធ្វើជាទាហានទេ?

ដាច់៖ អត់មានទាហានអីទេ បើទើបតែមកធ្វើនៅឆ្នាំ១៩៨៨ ។

កុសលៈ ទេ គឺអត់មានបានធ្វើជាទាហានវៃជាមួយនឹងវៀតណាមអីទេ?

ដាច់៖ មានបានទៅវៃឯណា បើមនុស្សទើបតែនិងភ័យដែរ គឺថាគេឲ្យនៅតែនឹងភូមិនេះឯង គឺថាអត់មានដែលបានទៅណាអីនឹងគេនោះទេ ដល់ពេលតែមកដល់៨៧នេះក៏ប្រុច ។

កុសលៈ ដូចថាពេលដែលកន្លងមកគឺលោកថាគ្រួសារលោកពូមិនដែលមានការកាប់សម្លាប់ មិនដែលបានគេចាប់ធ្វើទារុណកម្មអី តើលោកពូជឿថាមានការកាប់សម្លាប់អញ្ចឹងមែនដែលអត់នៅក្នុងសម័យនោះ?

ដាច់៖ ទេ បើតាមដែលគេលើកឡើងណា គឺមិនដឹងថាគេឃោសនាអីទេ គឺថាការលើកឡើងរបស់របបពាឆ្នាំ៨ខែ២០ថ្ងៃ ដោយមានបនប្រល័យពូជសាសន៍នោះណា ដែលមានអីអញ្ចឹងទៅ

គឺខ្ញុំមិនទាន់ថាយ៉ាងម៉េចទេ ពីព្រោះអីលឺតាមរយះមិត្តភ័ក្រដែលគេនិយាយខ្លះ គឺថាគេមានបងប្អូនគេនៅពេលនោះ គឺមានអាដែងគេធ្វើបាបអី ហើយលឺថាគេយកទៅដាក់គុកទួលស្លែង អីអញ្ចេះចុះទៅ ហើយខ្ញុំក៏មិនបានដឹងថាទួលស្លែងអីនៅឯណានោះទេ គឺថាមិនដែលបានស្គាល់អាទួលស្លែងនោះទេ ។

កុសលៈ តែក្រោយមកមានដែលបានទៅទួលស្លែងដែលទេ?

ដាច់ៈ អត់! តែបានទៅភ្នំពេញ នៅពេលដែលទៅទស្សនៈកិច្ចពីរឿងផ្នែកកសិកម្ម ពីរឿងបណ្ដុះផ្សិត ពីរឿងចិញ្ចឹមកូនត្រី ។

កុសលៈ តែលោកពូមិនដែលបានទៅទួលស្លែងទេ?

ដាច់ៈ តែធ្លាប់បានលឺ តែមិនដឹងជានៅត្រង់ណា ។

កុសលៈ សរុបមក តើលោកពូជឿដែរ តែត្រង់ថាស្លាប់ប៉ុណ្ណឹងថាការពិត?

ដាច់ៈ មិនដឹងត្រង់ថា វាមិនបានឃើញពិត គឺថាមនុស្សដែលវាមិនបានឃើញពិត អញ្ចឹងបានថាមកសួរខ្ញុំពីរបបនៅពេលនោះ គឺថាខ្ញុំចង់ទៅលោកក្មួយឯងវិញថា បើថាឪពុកមីងមាលោកក្មួយឯងនិយាយថាម៉េច ក៏ជាខ្ញុំនិយាយដែរពីរបបនៅពេលនោះណា គឺថាមិនខុសគ្នាទេ ប៉ុនគាត់ខ្លះគឺគាត់អាចខុសពីខ្ញុំ ដោយថាមានគ្រួសារលំបាកស្រួលអញ្ចេះចុះទៅណា ប៉ុនរបបនៅពេលនោះ បើតាមខ្ញុំតាមមើលគឺមិនអាចខុសគ្នាទេ តែវាអាចតាមតំបន់ តាមតំបន់គេនៅកន្លែងខ្លះគេធ្វើបាប ហើយកន្លែងខ្លះគឺគេស្រួលបន្តិចទៅ ព្រំដែនកន្លែងណាក៏លំបាកទៅ ហើយព្រំដែនកន្លែងណាក៏វាស្រួលទៅ អញ្ចឹងគឺវាអត់ដូចគ្នាប៉ុន្មានទេ ប៉ុនវាគ្រាន់តែថាជាទិសដៅរបស់គេតែមួយទេ គ្រាន់តែថាអាខ្លះក៏អនុវត្តវាខុសគ្នាខ្លះទៅណា ។

កុសលៈ អញ្ចឹងគ្រួសារលោកពូរស់នៅជាមួយគ្នានៅជំនាន់នោះ រហូតមកអត់មានបែកគ្នាទេ?

ដាច់ៈ គ្រួសារខ្ញុំ!

កុសលៈ បាទ!

ដាច់ៈ នៅនោះឯង ។

កុសលៈ ហើយគាត់ក៏គេឲ្យទៅតាមក្រុមផ្សេងៗដែរ?

ដាច់ៈ គេបែកទៅតាមនេះគេទៅ... ។

កុសលៈ ទៅតាមអាយុទៅ?

ដាច់ៈ ហ៊ឺ....ហ៊ឺ...គឺអញ្ចឹងទៅ ។

កុសលៈ ហើយចុះបងប្អូនពូប្រុស៥នាក់ទៅធ្វើអីដែរ នៅពេលនោះ?

ដាច់ៈ ទេ ដូចជាអត់មានឃើញធ្វើអីទេ គឺថាគាត់នៅតែនឹងផ្ទះទាំងអស់ ។

កុសលៈ ហើយចុះអត់មានទៅដាំដុះ ទៅចំការអីទេ?

ដាច់ៈ ហ៊ឺ! គឺទៅធ្វើតែស្រែចំការនៅជិតៗភូមិទេ ។

កុសលៈ ហើយចុះទៅលើកទំនប់នោះ គឺមានតែលោកពូម្នាក់ទេកាលនោះ?

ដាច់ៈ ទេ កាលនោះគឺទៅតែខ្ញុំមួយទេ ជំនាន់យើងដែលស្អីនេះ.... បងខ្ញុំនោះណា និយាយពីបងខ្ញុំម្នាក់វិញទៅណា កាលនោះគឺគាត់លើកទំនប់នៅជាមួយខ្ញុំដែរ តែគាត់មកបានតែប៉ុន្មានថ្ងៃស្រាប់តែគាត់ឈឺទៅ គេក៏ឲ្យគាត់ត្រឡប់ទៅដេកពេទ្យវិញទៅ អញ្ចឹងបានតែថាសឹងតែនឹងអត់ពីព្រោះថាគាត់មកបានតែពីរ-បីថ្ងៃអី បើខ្ញុំបាន៣ខែគត់ ។

កុសលៈ អញ្ចឹងនៅក្នុងរបបបីឆ្នាំនោះ តើលោកមានជំទាស់នឹងគោលការណ៍មាគ៌ានយោបាយអីគេដែលទេ ដូចថានៅពេលដែលប្រជុំអី គឺលោកពូឡើងជំទាស់ថាខ្ញុំមិនពេញចិត្តកន្លែងនេះមិនពេញចិត្តកន្លែងនោះអីដែលទេ?

ដាច់ៈ ពេញចិត្តឬក៏មិនពេញចិត្តអី អារបបនៅពេលនោះ ទោះជាពេញចិត្តក៏មិនមាត់ ហើយអាមិនពេញចិត្តក៏មិនមាត់ដែរ នៅក្នុងរយៈ៣ឆ្នាំ៨ខែ២០ថ្ងៃនោះគឺថា មិនមានអ្នកណាមួយហ៊ានកំរើកនោះ ទោះជាពេញក៏មិនមាត់អាមិនពេញក៏មិនមាត់ គឺថាខ្ញុំចង់និយាយអញ្ចឹងទៅណា ។

កុសលៈ ចុះមានពេលខ្លះមាននិយាយថាមិនពេញចិត្តត្រង់កន្លែងណាឬមិនពេញចិត្តកន្លែងណាដែលទេនៅក្នុងរបបនោះ?

ដាច់ៈ ខ្ញុំមើលឃើញពេញ អាកន្លែងដែលពេញទេណា នៅកន្លែងខ្ញុំគឺមិនដែលធ្លាប់ដែលបានឃើញទេណា តែធ្លាប់តែលឺគេថា អញ្ចឹងខ្ញុំគិតថា អាកន្លែងដែលមិនពេញ គឺខ្ញុំគិតឃើញថាត្រង់កន្លែងដែលគេកាប់សម្លាប់អញ្ចឹងទៅណា អាត្រង់នឹងគឺខ្ញុំមិនពេញចិត្តទេ ។

កុសលៈ តែលោកពូមិនដែលបានឃើញទេ?

ដាច់ៈ មិនដែលបានឃើញទេ តែគ្រាន់តែលឺគេថាណា ប៉ុនបើត្រង់ទស្សនៈរបស់នៅត្រង់នេះ គឺថាខ្ញុំមិនពេញចិត្តទេ គឺជំទាស់អារឿងកាប់សម្លាប់អញ្ចឹងណា ហេយការពេញចិត្តគឺការងារដែលមានទទួលមានប្រលាយគឺខ្ញុំមានការពេញចិត្តដែរ ប៉ុនអារឿងដែលថាស៊ីមិនសូវឆ្អែតហើយកាត់សម្លាប់ទៀត គឺខ្ញុំទាស់តែត្រង់នោះឯង ។

កុសលៈ ហើយបានជាញុំាមិនសូវឆ្អែត បើអង្ករយើងធ្វើបានច្រើន?

ដាច់ៈ អានេះខ្លាចកន្លែងគេខ្លះទេណា ដែលគេនិយាយនោះណា ។

កុសលៈ ចុះបើធ្វើស្រែគ្រប់គ្នា ហេតុអីបានជាហូបមិនគ្រប់ ខ្ញុំឆ្ងល់មែនទែន?

ដាច់ៈ មកពីគេមិនឲ្យហូបណា ។

កុសលៈ ហើយចុះអង្ករយកទៅណាអស់ទៅ?

ដាច់ៈ មិនដឹងជាទៅឯណា ហើយក្មួយឯងយល់ដែលទេ ថាគេយកទៅណានៅពេលនោះ បើខ្ញុំមិនដឹងដែរនោះ ។

កុសលៈ ហើយសុទ្ធតែបីគោននៅក្នុងមួយហិចតា?

ដាច់ៈ បើធ្វើមួយហិចតាបីតោ អានេះគឺលើកជាគោលការន៍របស់គេ អានឹងមិនដឹងជាយ៉ាងម៉េចគឺថាក្មួយឯងឆ្ងល់ដូចខ្ញុំដែរ មិនដឹងជាគិតថាម៉េច ។

កុសលៈ ចុះពូមានដែលឃើញ ដូចជាអង្ករដូចជាអីហ្នឹងលើកដាក់ឡានទៅណាទៅណីអីដែលទេ?

ដាច់ៈ ទេ មិនបានជាតាមដានអារឿងអីអញ្ចឹងៗទេ ។

កុសលៈ ហើយចុះមានដែលឃើញ ជនជាតិចិនអីគេចុះមកដែលទេ នៅពេលនោះ?

ដាច់ៈ ពួកកសិករនៅចុងកាត់មាត់ញកអីមិនមានទេ ករណាស់?

កុសលៈ ដូចជានៅក្នុងការដ្ឋានអី?

ដាច់ៈ ទេ អត់មានទេ កំរណាស់ គឺមិនមានទេ ។

កុសលៈ ខ្ញុំសួរពូមកដល់ពេលនេះ គឺចង់សួរសំនួរធំមួយទៅពូ ហើយសំនួរធំនោះ តើពូធ្វើម៉េចទៅដើម្បីឲ្យមានការផ្សះផ្សារ បើតាមដែលពូយល់?

ដាច់ៈ ទេ មិនដឹងជាកាលណោះមិនដឹងជាយ៉ាងម៉េចបានជាផ្សះផ្សារ បើខ្ញុំទើបតែនឹងចូលមក ។

កុសលៈ អត់ទេ គឺខ្ញុំចង់សួរពូថាតើយើងធ្វើម៉េចដើម្បីឲ្យមានការផ្សះផ្សារ ហេតុអីបានជាខ្ញុំសួរសំនួរនេះទៅពូ ពីព្រោះថាប្រទេសយើងហាក់ដូចជាមានពីរក្រុម មានសង្គមពីរ គឺដូចថាមួយក្រុមទៀតនៅខាងក្រៅ ហើយមួយទៀតនៅខាងក្នុង ហើយអ្នកដែលនៅខាងក្នុងគឺគេមានបងប្អូនបាត់ ហើយស្លាប់ អញ្ចឹងគឺគិតតែពីរថាត្រូវនាំអ្នកនេះមកកាត់ទោអ្នកនោះមកកាត់ទោស ហើយអ្នកដែលនៅខាងនេះក៏គាត់មានប្រវត្តិរបស់គាត់តស៊ូក៏ឈឺចាប់ដែរ ហើយដោយសារតែលោកពូជាអ្នកគ្រប់គ្រង ហើយលោកពូអាចពិភាក្សាជាមួយអ្នកភូមិ អញ្ចឹងគឺលោកពូអាចដឹងលឺច្រើន អញ្ចឹងខ្ញុំចង់សួរថាតើធ្វើម៉េចទៅដើម្បីឲ្យមានការផ្សះផ្សារ កុំឲ្យមានក្នុងនឹងមានក្រៅ អានឹងគឺសំនួរធំរបស់ខ្ញុំនៅត្រង់កន្លែងហ្នឹង ដែលខ្ញុំសួរពូពីដើមមកគឺចង់ដឹងនៅត្រង់ហ្នឹង?

ដាច់ៈ អានេះគឺតាមដែលខ្ញុំយល់ខ្លួនខ្ញុំទេណា ពីព្រោះខ្ញុំមិនដែលបានធ្វើអី ដល់អញ្ចឹងចូលវិករ៉ិនចូលទៅសាលារៀនសូត្រគឺអត់បានជ្រៅជ្រាក់ទេ ហើយកំរតក៏វាទាបផង គឺខ្ញុំបានរៀនបានតិចណាស់ដែរ តែការយល់ដឹងរបស់ខ្ញុំ មូលហេតុដែលបានផ្សះផ្សារគ្នា ដែលមានក្នុងមានក្រៅគឺក្មួយឯងមិនថាអីចឹងមិញ អីចឹងតើអ្នកណាដែលត្រូវផ្សះផ្សារគ្នាកើត ដែលចង់និយាយថា

ការផ្សះផ្សារហ្នឹង ខ្ញុំមើលឃើញដោយមានការ គិតឃើញដោយខ្លួនឯងទេណា អានេះគឺជាចិត្តខ្ញុំទេណា តែរូបខ្ញុំគឺនៅឯណោះនៅឡើយទេ អ៊ីចឹងគឺខ្ញុំលើកថាពួក ប៉ុល ពត ទៅចុះ ហើយនៅខាងណោះគឺយើងមិនតស៊ូជាមួយរដ្ឋកម្ពុជា ហ៊ុន សែន មិនអ៊ីចឹង ដល់តែចឹងនៅខាងណោះគឺចេះតែវៃគ្នាជាមួយនិង ប៉ុល ពត តើស្រណាំមូលហេតុអីដែលគេត្រូវចូលមកនោះ បើតាមដែលខ្ញុំវិភាគគិតថា គឺទី១គឺមានសង្គ្រាមយូរអង្វែងផង ដូចថាវាវិចវិលណាគឺថាវាធ្ញើយូរៗទៅ ដូចថាវាអស់សង្ឃឹមនិងការស្មាននេះ ម៉្យាងអស្សឹមដែលគ្មានការរីកចំរើននោះណា ហើយដល់អ៊ីចឹងមិនថាមេតូចមេធំទេ ដល់តែយូរៗក៏ក្ដួងចូលទៅទាំងអស់ ហើយក៏មានការផ្សះផ្សារបណ្ដោយទៅ អ៊ីចឹងនេះគឺគ្រាន់តែគំនិតខ្ញុំដែលវិភាគដោយខ្លួនឯងទេ ពីព្រោះថាខ្ញុំនៅខាងនោះដែរ ។

កុសលៈ តើលោកពូចូលមកជាមួយបង ផាន់ណា ដែរ?

ដាច់ៈ បង ផាន់ណា និងណា ។

កុសលៈ អ៊ីចឹងនៅក្រុមជាមួយគ្នា?

ដាច់ៈ បង ផាន់ណា គាត់នៅរលួស គឺភូមិគាត់ ដែលពេលនៅទ័ពគឺគាត់ចូលទៅពីនេះ ។

កុសលៈ តើបងនៅទ័ពជាមួយគាត់?

ដាច់ៈ អត់ទេ ។

កុសលៈ អ៊ីចឹងលោកពូផ្ដាច់ខ្លួនទៅក្រោយទេ?

ដាច់ៈ ទៅក្រោយនេះទេ ទើបតែមកយើងនៅក្រោយពេលសមាហរណ៍កម្មតិចនេះទេ គឺ៨៧ ។

កុសលៈ អ៊ីចឹងនៅជាមួយពូនឹមពូអី នៅតាមជើងភ្នំនេះហើយមើលទៅ?

ដាច់ៈ ខ្ញុំនៅចេះគឺមុនដែលខ្ញុំនៅ គឺដោយសារតែខ្ញុំមកតាមគេមក គឺពួកខាង៩២០៦ណោះទេ គឺដោយសារតែគេឆ្លងកាត់អែបផ្ទះខ្ញុំអ៊ីចឹងទៅក៏ មកៗជាមួយគេអ៊ីចឹងទៅហើយសុំគ្រួសារខ្ញុំនេះមកបណ្ដោយទៅ ដល់តែពេលមកទៅក៏គេផ្សះផ្សារបណ្ដោយទៅ អ៊ីចឹងរឿងរ៉ាវដែលយើងមិនសូចក្ដាប់បាននឹងគេ គឺដោយសារតែអ៊ីចឹងទេ ហើយលឺតែគេថាទេគឺយើងមិនសូវជាយល់អីដែរទេ ។

កុសលៈ អ៊ីចឹងឥឡូវតើលោកពូគិតថាមានលំនឹងនៅក្នុងជីវភាពរស់នៅ គឺមានជីវភាពរស់នៅ និយាយរួមទៅគឺមានសុវត្ថិភាពនៅក្នុងការរស់នៅ ហើយមិនចង់ទៅណាទៀតទេ?

ដាច់ៈ ខ្ញុំនេះគឺពេញហើយនេះ គឺខំដាំដូងសម្បើមហើយនេះ គឺកំពុងតែពេញលក្ខណៈហើយមិនឃើញទេ សូម្បីតែមានសភាពដែរមានជម្លោះតិចតួចអី ។

កុសលៈ គ្រាន់តែឃើញដីកត្រង់សេ គឺដឹងតែថាមិនចង់ទៅណាហ្នឹង?

ដាច់៖ ទោះបីជាមានជម្លោះតិចតួចអី ហើយរដ្ឋគេថាឲ្យជម្លៀសកូនចៅអី គឺថាឲ្យកូនចៅទៅហើយ ចំណែកខ្ញុំគឺនៅនេះឯងមិនទៅណាទេ ពីព្រោះថាភូមិឋានយើងនៅនេះណា ហើយក៏មានទឹកដីស្រែភ្លឺយើងអីនៅនេះស្រេចទៅហើយ ហើយដល់អីចឹងគឺខំដឹកត្រង់សេនឹងទៅ ពូកដីទេអ នេះគឺមិនមែនដឹកទេ គឺពួកដីធ្វើដូចជាប៉ារ៉ែត ។

កុសលៈ អីចឹងគឺខ្ញុំសុំសួរតទៅទៀត តើចុះបើសិនជារដ្ឋាភិបាលគាត់មានគោលការណ៍មយ ដើម្បីផ្សះផ្សារន ដូចថាធ្វើសមាហរន្និកម្ម បញ្ចូលពួកអតីតដែលនៅតំបន់នេះឲ្យទៅជាផ្នែកមួយរបស់រដ្ឋាភិបាល ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងដោយរដ្ឋាភិបាល ហើយខ្ញុំឃើញថាមានការអភិវឌ្ឍន៍បានលឿនមែន បើប្រៀបធៀបទៅនឹងស្រុកផ្សេងៗណា?

ដាច់៖ គឺបានសមរម្យ ។

កុសលៈ ប៉ា! គឺសមរម្យ សូម្បីតែថ្នាក់ភូមិនោះក៏មានរបៀបត្រឹមត្រូវជាង បើសិនជាប្រៀបធៀបទៅខាងព្រៃវែង ស្វាយរៀង តាកែវអីគឺនៅខាងនោះគឺនៅតែយ៉ាប់ច្រើនមែនទែន បើសិនប្រៀបធៀបមកនៅតំបន់នេះ?

ដាច់៖ នៅខាងណោះគឺខ្ញុំមិនសូវជាយល់ទេ នៅខាងណោះនោះ ។

កុសលៈ អីចឹងខ្ញុំឆ្ងល់ថា តើហេតុអីបានជាមានការផ្សះផ្សារអីចឹងហើយ ហេតុអីបានជានៅមានតុលាការទៀត គឺលោកពូប្រហែលជាបានដឹងខ្លះហើយ គឺធ្វើកាត់ទោសលោក នួន ជា ខៀវ សំផន អី?

ដាច់៖ គឺលឺតែនៅតាមវិទ្យុ ស្តាប់លឺតាមតែវិទ្យុហើយការយល់នោះក៏វាតិចណាដែរ ។

កុសលៈ ប៉ុន្តែលោកពូយល់ថាម៉េចដែរ នៅពេលដែលលឺថាអីចឹងៗ តើវាមានការប៉ះពាល់ដល់ការផ្សះផ្សរបែបណា?

ដាច់៖ គឺវាប៉ះណាស់ឯងបើគិតទៅនោះ បើយើងគិតទៅគឺវាឲ្យតែកាត់មួយគឺកាត់ទាំងអស់ហើយ ពីព្រោះអីនៅពេលនោះ គឺសុទ្ធតែជាពួករបបប្រលៃមិនអីចឹង គឺពួក៣ឆ្នាំ៨ខែ២០ថ្ងៃ ហើយដល់អីចឹងគឺកាត់ទោសគឺសុទ្ធតែជាពួកតាៗប្រភេទនឹងឯង គឺខៀវ សំផន អីនឹងឯង តែខ្ញុំមិនដឹងជាមានអ្នកណាៗខ្លះទេ ឥឡូវមិនសូវជាបានស្តាប់រ៉ាដ្យូផង ។

កុសលៈ ខៀវ សំផន. អៀង ធីរិទ្ធ ដែលគាត់ធ្វើការនៅក្រសួងវប្បធម៌ និងខាងសុខាភិបាល. អៀង សារី គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយពូមិនដែលជួបមែនទេ?

ដាច់៖ គឺលឺតែតាមវិទ្យុទេ ។

កុសលៈ ហើយនឹង តា នួន ជា ដែលគាត់បន្ទាបញ៉ពី ប៉ុល ពត ណាគឺទាំង៤រូបហ្នឹង ហើយ ឌុច នោះ គឺគេកាត់មុនហើយមិនអីចឹង?

ដាច់:	លឺហើយ ។

កុសល:	គឺគេកាត់មុនហើយ?

ដាច់:	លឺហើយ គឺលឺតាមតែវិទ្យុទេ ។

កុសល:	អីចឹងគឺលោកពូតាមដានតាមវិទ្យុដែរមិនអីចឹង?

ដាច់:	បាទ! ស្តាប់ដែរ តែស្តាប់ជាមួយបង តែយូរៗបានស្តាប់ម្តង ។

កុសល:	អីចឹងបើសិនជាសំនួរខ្ញុំ គឺវាមិនជួយទៅនិងការផ្សះផ្សារហើយមិនអីចឹង បើសិនជាមានការកាត់ទោសអីចឹង ឬក៏យ៉ាងម៉េចដែរ?

ដាច់:	ទេអារឿងត្រង់នឹងបើគិតទៅ គឺខ្ញុំអានេះគឺជាការតាមដានរបស់ខ្ញុំ គឺថាផ្សះផ្សារគឺផ្សះផ្សារហើយ ហើយការដែលកាត់ទោសគឺវាមិនស្របទៅនឹងការផ្សះផ្សារមិនអីចឹង?

កុសល:	បាទ! គឺវាជួយ តើស្របឬក៏មិនស្របបើតាមពូ?

ដាច់:	បើតាមមតិខ្ញុំគឺគេ ចំរាញ់យកតែអ្នកដែលពីជំនាន់មុននោះណា គឺតុលាការគេកាត់ពីជំនាន់មុននោះគឺខ្ញុំមិនយល់ទេ អីចឹងគឺខ្ញុំយល់ថាវាស្របទៅនឹងអានេះ គឺស្របនឹងអាផ្សះផ្សារត្រង់ថា ក្រែងថាយើងមិនធ្វើអីចឹង គឺថាក្រែងគេមិនជឿណា គឺគេមិនជឿថាតាៗនៅក្នុងជំនាន់គាត់គេធ្វើអីចេះៗនោះណា គឺធ្វើឡើងចង់ដឹងការពិតនោះឯង ។

កុសល:	គឺគេចង់ដឹងការពិត?

ដាច់:	គឺគេចង់ដឹងការពិតនោះឯង បើថាមិនអីចឹងគឺមិនឃើញការពិតនោះទេ ពីព្រោះគេមិននិយាយបើសិនណាជាគេមិនធ្វើអីចឹង តើមានអីនឹងចេញជាភស្តុតាងមិនអីចឹង អានេះគឺគ្រាន់តែជាការយល់របស់ខ្ញុំ ។

កុសល:	ប៉ុន្តែលោកពូឬក៏អ្នកភូមិអាចបារម្ភណ៍ថានិងការប៉ះពាល់ដល់ការផ្សះផ្សារដែររឺទេ ចំពោះតុលាការហ្នឹង បើសិនជាអាចប៉ះពាល់ តើវាមានការប៉ះពាល់យ៉ាងម៉េចខ្លះដែរ?

ដាច់:	គឺថាមិនរអើលអីទេ ។

កុសល:	មិនរអើលទេ?

ដាច់:	គឺវាគ្រាន់តែប៉ះទៅដល់អ៊ំហើយនឹងតាៗយាយប៉ុន្មាននាក់ប៉ុណ្ណឹងទេ ។

កុសល:	អីញ្ចឹងលោកពូគាំទ្រឲ្យមានតុលាការហ្នឹង?

ដាច់:	បាទ! ហើយបើនិយាយពីតុលាការនេះ បើគិតទៅខ្ញុំថាបើកាត់ទៅគឺវាក៏ល្អម្យ៉ាងដែរ ល្អត្រង់ថាកុំឲ្យមនុស្សនោះវាមានអំពើនឹងតទៅទៀត អីចឹងក៏មិនឲ្យមានអ្នកណាទៀតទេ បើមានត្រឹមប៉ុនណាគឺមានត្រឹមប៉ុននង់ទៅ ។

កុសល:	អីចឹងមិនចង់ឲ្យមានការកាត់លើសពីតាៗនឹងទេ?

ដាច់៖ គឺកុំឲ្យមានកាត់អីទៅណាទៅទៀត កាត់ធ្វើអីពីព្រោះថាអ្នកដែលក្រៅពីនោះកគេមិនដឹងអីដែរ គឺវាអីចេះ ។

កុសលៈ ចុះអ្នកដែលទទួលធ្វើតាមតែបញ្ជារគេគួរតែយកទៅកាត់ទោសដែរអត់?

ដាច់៖ ក្តែលទៅយកធ្វើអីអ្នកធ្វើតាមគេនោះ គឺគេធ្វើតាមតែគេតើនៅជំនាន់នោះ តែគេឲ្យធ្វើអីគឺធ្វើនោះហើយ បើសិនជាគេឲ្យធ្វើអីគឺធ្វើតាមនោះឯង ហើយដូចជារបបនោះគឺក្មួយឯងមិនដឹង ហើយក៏ដូចជានៅជំនាន់នោះក៏ដោយ ឧទាហរណ៍ថា តែគេថាក្មួយឯងមិនបានរៀនចប់អីចឹងគឺមិនក្មួយឯងមិនទៅរៀនតាមគេ គឺមិនធ្វើតាមគេមិនអីចឹង១ ហើយយើងមិនរៀនទៅតាមគេ ហើយតែរៀនទៅតាមគេហើយ តើយើងទៅធ្វើខុសក្បួនម៉េច គឺមានតែអីចឹង ។

កុសលៈ ចុះខុចនោះគឺគេមិនកាត់ទោសកាត់មុនគេ ហើយឌុចគាតមិនជាប្រធានស-២១ គឺជាប្រធានគុកទួលស្លែងណា?

ដាច់៖ អាធាតុកុធាតុអីនោះ គឺលឺតែតាមចវិទ្យុហ្នឹង ។

កុសលៈ តែគាត់គឺធ្វើតែតាមគេដែរ តើគាត់គួរតែទទួលខុសត្រូវដែរទេ?

ដាច់៖ បើតាមនេះទៅ គឺគាត់ជាមេខ្លោងមួយ គឺចង់និយាយថាគាត់ជាមេខ្លោង ហើយគាត់មិនមែនជាតូចនោះទេ តែគ្រាន់តែចង់ថាមិនចង់រីករាលដាលទៅណាទៀត គឺតែមួយនឹងគឺល្មមដឹងរឿងសប់អីថាវាចេះៗហើយ ហើយបើសិនជាស្រាវជ្រាវរកវ៉ាវៗឯណាទៀតអីគឺខ្ញុំមិនពេញចិត្តនោះទេ គឺមិនអាច ។

កុសលៈ អីចឹងគឺខ្ញុំជិតដល់សំនួរចុងក្រោយហើយ មុននឹងឈានដល់ការអភិវឌ្ឍន៍ភូមិស្រុកណាលោកពូ គឺទាក់ទងទៅនឹងការផ្សះផ្សារ ទីមួយតើយើងបើគិតទៅដល់របបពាឆ្នាំហ្នឹង តើប្រជាជនយើងគួរតែទប់កំហឹងនៅក្នុងចិត្ត គួរតែបំភ្លេចចោលគួរតែយើងធ្វើយ៉ាងម៉េច ឥឡូវយើងឈប់និយាយពីរឿងតុលាការ ពីព្រោះថារឿងតុលាការហ្នឹងគឺគេកាត់តែមនុស្ស៤-៥នាក់ទេមិនអីចឹង តែជំនួនជនរងគ្រោះនោះគឺវាមានច្រើន ហើយអ្នកដែលប្រព្រិត្តនេះគឺវាមានផ្សេង ហើយអ្នកដែលមានកំហុសតូចតាចទៀតនោះក៏វាមានផ្សេង ហើយវាមានធំតូចអីណាលោកពូ តើយើងធ្វើម៉េចអំពីរបបនោះកុំឲ្យមានការគុំគួនគ្នាតទៅទៀត អានេះគឺជាការផ្សះផ្សាររវាងប្រជាជននឹងប្រជាជន គឺថាអ្នកនៅក្រោមៗផ្សះផ្សារគ្នា ហើយពាក្យដែលថាផ្សះផ្សារមានន័យថាម៉េចដែរទៅពូ ចំពោះប្រជាជនយើងដែលនៅខាងក្រោយមានន័យថាម៉េចដែរទៅ?

ដាច់៖ វាអស់ហើយ គឺវាលែងជឿហើយ ពីព្រោះអីវានៅពេលនោះគឺវាមានកំហឹងមែនហើយ ដូចថាគាត់នេះគឺគាត់មានកំហឹង ហើយដល់មកឃើញរបបសព្វថ្ងៃនេះ គឺយើងមើលឃើញ

ទៅគឺថាវាធ្វើហើយគឺដើម្បីឲ្យវាអស់ចិត្តរបស់ពួកគាត់ អានេះគឺខ្ញុំនិយាយពីរឿងតុលាការនោះណា គឺយកទៅវត្តពោធិ៍ពិឃាដ គឺដោយសារតែពួកនេះហើយ គឺខ្ញុំចង់និយាយអីចឹងណា ហើយម៉្យាងទៀតក៏លើកស្ទួយដូចជានៅសព្វថ្ងៃនេះណា គឺលើកស្ទួយដល់ប្រជាពលរដ្ឋគឺជារូម ដែលគេហៅថាគិតលប់ គឺលប់អាការលំបាករបស់គាត់ឬក៏ជាសាច់ឈាមរបស់គាត់ដែលបានកន្លងមក គឺឃើញថាបងប្អូនភាគច្រើនគឺគាត់លប់លាង ហើយតើទៅរកហេតុផលត្រង់ណាទៀតដែលថាពួកគាត់មិនលប់លាងនោះ គឺគាត់អាចមានអារម្មណ៍មួយថាពួកគាត់លប់លាង តែយកស្អីមកលប់លាង អីចឹងសព្វថ្ងៃគឺវាជាការកែឆ្នៃ លើកតំកើងដល់ប្រជាពលរដ្ឋ លើកដូចជាងគ្រប់បែបយ៉ាង បើតាមដែលខ្ញុំមើលពីដើម គឺតាមចាស់ៗគាត់ធ្លាប់និយាយគឺគាត់ថា គឺនិយាយពីការកសាងជីវភាពប្រជាពលរដ្ឋនៅគ្រប់ភូមិគ្រប់ឃុំណា បើគិតទៅគឺវាមើលស្រាលដែរ តែដល់តែមកសព្វថ្ងៃនេះគឺមើលទៅគឺវាមានសព្វស្មើគ្រាន់ គឺនិយាយរួមបួនជិះមកគឺឃើញហើយមែនណ៎ គឺយើងមើលឃើញដូចគ្នាមិនចាំបាច់ខ្ញុំនិយាយច្រើននោះទេ ។

កុសលៈ អីចឹងយើងគួរតែបំភ្លេចរបបនឹងចោល ឬក៏យើងចាំបាច់គួរតែសរសេរប្រវត្តិសាស្ត្រនេះឡើងវិញ?

ដាច់ៈ គឺយើងសរសេរជាប្រវត្តិសាស្ត្រទុកជាទៅចុះ បើទោះជាយើងមិនក៏មានគេជាអ្នកទុក គឺខ្ញុំឃើញគេលើកទុកដាក់ជាប្រវត្តិសាស្ត្រមួយជំនាន់ខ្មែរក្រហមទៅហើយ គឺគេដាក់អីចឹងទៅហើយនោះ ។

កុសលៈ ឬក៏យើងគិតថាជារឿងដែលកន្លងផុតទៅហើយ?

ដាច់ៈ ជារឿងដែលផុតទៅហើយ តែគ្រាន់តែគេទុក គេទុកជារឿងប្រវត្តិសាស្ត្រមួយ ដើម្បីឲ្យដែលគេហៅថាជំនាន់ក្រោយៗណា ឲ្យវាបានឃើញអីចឹងទៅ ។

កុសលៈ តែយើងគួរតែមានការអត់អោនទោសគ្នាទៅវិញទៅមកដែលឬទេ?

ដាច់ៈ ហ្នែ៎ គេអត់អោនហើយតើសព្វថ្ងៃនេះ ។

កុសលៈ តើគួរតែជណដៃដល់នោះចេញមកដើម្បីសុំទោស ហើយប្រាប់ថាគាត់បានធ្វើអីចឹងមែនតែតាមតែបញ្ជារគេមកទេ តើគួរតែមានការអត់អោនទោសរវាងជនរងគ្រោះហើយនឹងជនដៃដល់ដែលរឺទេលោកពូ?

ដាច់ៈ ទេ អានេះបើសិនជាមេៗគឺខ្ញុំមិនដឹងទេ បើថាគាត់ធ្វើបានគឺគាត់ធ្វើទៅ អានេះគឺមេៗទេបើឥឡូវនៅខាងក្រោមៗនេះគឺគ្មានទេ គឺនៅខាងក្រោមនេះគឺវាស្ងាត់អស់ទៅហើយ?

កុសលៈ តើមានន័យថាម៉េចដែរទៅពូ ស្ងាត់អស់ហ្នឹង?

ដាច់៖ គឺវាស្ងាត់ត្រង់ថាសាច់ឈាមរបស់គេ ដែលអាចមានគ្រោះថ្នាក់ពីពេលនោះ ហើយដល់តែមកដល់ឥឡូវក៏គេមិនថាម៉េច ហើយគេបានយកឈ្មោះតាប៉ុន្មាននាក់នោះទៅកាត់ទោសទៅហើយនោះ ដូចថាគេអស់ចិត្តអស់ថ្លើមរបស់គេណា នែគឺវាអីចឹងណា ហើយក៏គេមិនអាចជាមានចង់គំនុំអីតទៅទៀតដែរ បើគិតពីជំនាននោះ បើសិនជានិយាយពីតាមពុទ្ធទំនាយវិញគឺតាមដែលព្រះពុទ្ធនោះ ដែលជាការទស្សទាយនោះណា....ស្អីទេ

កុសលៈ គឺពារវំរាប់ដោយសារមិនចង់ពារនោះ?

ដាច់៖ អ៊ឺ គឺវាទៅអីចឹងដែរ គឺជាការទស្សទាយ

កុសលៈ អីចឹងគឺលោកពូជឿទៅលើសាសនាព្រះពុទ្ធដែរ ជឿទៅលើកម្មពារដែរ

ដាច់៖ គឺជឿទៅលើសាសនាហើយ គឺវាមានមួយក្រលាក់គឺវាអីចេះ ចាស់ៗគេថាម៉េចទេ ប្រើសំរូចស្នែងពួននៅតាមចាំចាក់អីគេ ខ្ញុំវាមិនចាំនោះណា ។

កុសលៈ ចុះលោកពូជឿលើបុណ្យបាបហើយជឿលើកម្មពារដែលទេ?

ដាច់៖ កម្មពារនោះគឺយើងមិនដឹងជាធ្វើម៉េចទេ ពីព្រោះថានៅជំនាន់នោះគឺវាទៅអីចឹង ដូចជាមកសព្វថ្ងៃនេះគឺវាចូលមកក្នុងការកំពង់តែអភិវឌ្ឍន៍ តែបន្តិចទៀតទៅវាប្រែទៅជាលម៉េចវិញអានោះគឺយើងមើលម៉េចទៅនិងឃើញ តែបើថាធ្វើល្អគឺវាបានលយូរទៅ មិនអីចឹង ។

កុសលៈ ពូអាសារទៅវត្តទៅវ៉ាអីដែលតើ?

ដាច់៖ ខ្ញុំអាសារបានទៅខ្លះដែលតើ លឺលោកទេសលោកអីដល់អីចឹងបានស្តាប់ ។

កុសលៈ ចុះលោកពូនៅក្នុងភូមិសន្តិភាពនេះ តើប្រជាជនមានការទុកចិត្តគ្នាទៅវិញទៅមកដែលទេ?

ដាច់៖ អត់អីទេក្មួយ គឺថា៨០ភាគរយគឺថាអាចពឹងពាក់គ្នាបានចឹងហ្នង គឺថា៨០ភាគរយទៅ មិនចាំបាច់ច្រើនពេកដល់ទៅមួយរយនោះទេ ពីព្រោះខ្ញុំធ្លាប់ស្ទៀបស្ទង់ ហើយខ្ញុំគ្រប់គ្រងតាំងពី៨៨មកម៉្លេះ អរ! ៩៨ ។

កុសលៈ ចុះលោកពូយល់ព្រមឲ្យរដ្ឋាភិបាលយល់ព្រមកាត់បន្ថយជនបរទេសដែលទេ ដែលលោកពូធ្វើជាប្រធានភូមិ គឺលោកពូបានដឹងខ្លះហើយថា គឺស្រុកយើងឥឡូវបើកចំហរ ហើយមានជនបរទេសចូលមកសព្វបែបយ៉ាង?

ដាច់៖ អត់អីទេ ភូមិខ្ញុំគឺគាំទ្រ ទោះជាអ្នកណាមកក៏បានដែរអត់អីទេ ។

កុសលៈ គឺទូទៅហ្នង?

ដាច់៖ ទូទៅ គឺថាអត់មានពិបាកទេ គឺថាមិនថាជនជាតិណាៗអីទេ ។

កុសលៈ ពូមិនព្រួយបារម្ភអីទេ ?

ដាច់៖ មិនព្រួយបារម្ភអីទេ ហើយបើថាចង់ទាក់ទងពីរឿងអី អភិវឌ្ឍន៍អីរឿងគឺមកចុះ នេះគឺភូមិរបស់ខ្ញុំគឺអត់មានបញ្ហាអីទេ បើថានៅភូមិគេគឺអត់មានដូចជានៅភូមិខ្ញុំនេះទេ?

កុសល៖ ចុះលោកពូគិតថារដ្ឋាភិបាលសព្វថ្ងៃ អាចផ្តល់សេចក្តីសុខដល់ក្រុមគ្រួសារលោកពូដល់កំរិតណាដែរ បានខ្លាំងឬក៏ខ្សោយ តិចឬក៏ច្រើន?

ដាច់៖ ខ្ញុំថាបានច្រើនគ្រាន់ហើយ ទីមួយគឺថាឲ្យមានសេរីភាពស្មើគ្នាណា ។

កុសល៖ ពូយល់ថាពេលថ្ងៃនេះគឺមានភាពស្មើគ្នា?

ដាច់៖ ទេ!ស្មើ ម៉េចដែលគេហៅថាភាព Gender នោះ ហាស៎ៗ! ហាស់ ហាស់...។

កុសល៖ ចុះប្រព័ន្ធតុលាការវិញ ឧបមារថាលោកពូមានរឿងក្តីក្តាំង ឧបមារថាមានរឿងជម្លោះដីធ្លីអីគឺថាឧបមារអីចេះចុះ តើលោកពូយល់ថាពេលដែលលោកពូទៅដល់តុលាការខេត្ត ស្រុកអីតើតុលាការនោះអាចរកយុត្តិធម៌ឲ្យលោកពូបានដែលទេ?

ដាច់៖ បាន ពីព្រោះខ្ញុំធ្លាប់ទៅពឹងពាក់ឲ្យជួយដោះស្រាយដី ជូនប្រជាពលរដ្ឋខ្ញុំដែរ គឺទៅដល់កន្លែងស្រុក គឺគេរកឲ្យបាន ពីព្រោះប្រជាពលរដ្ឋខ្ញុំដែលមានបញ្ហាកើតឡើងរឿងដីជាប់ជាមួយនឹងដីពួកក្រុមហ៊ុនណា ដល់អីចឹងគឺខ្ញុំទៅជួយដល់ប្រជាពលរដ្ឋខ្ញុំ គឺមានឃុំហើយនឹងស្រុកជាអ្នកជួយអន្តរាគមន៍ជាមួយក្រុមហ៊ុន ហើយកាលមុនខាងក្រុមហ៊ុនគេថា ហ្អែងបោះបង្គោលទៅកន្លែងនេះចេះៗៗទៅ ហើយដល់ពួកប្រជាពលរដ្ឋដែលប៉ះពាល់ដល់ដីគាត់ ហើយគាត់ទៅតវ៉ាទៅ ហើយមេក៏បញ្ជារមកវិញថា ហ៊ឺកពួកហ្អែងដកផ្លាកចេញសិន គឺវាចូលទៅដល់ដីគេហើយ ហើយខ្ញុំបានឃើញថាការដោះស្រាយនោះគឺវាមានភាពយុត្តិធម៌ដែរ នេះខ្ញុំពីព្រោះថាខ្ញុំទៅផ្ទាល់ ។

កុសល៖ ចុះបើសិនជាលោកពូមិនពេញចិត្តនិងរដ្ឋាភិបាល តើលោកពូហ៊ានរិះគន់កែលំអរដែលទេ?

ដាច់៖ ទេ! អត់ខ្លាចទេខ្ញុំ បើថាកន្លែងណាដែលវាខុសគឺយើងជួយតំរង់វាអីចឹងមក ។

កុសល៖ លោកពូជួយតំរង់?

ដាច់៖ ចា៎! កន្លែងណាដែលវាខុសឆ្គងគឺយើងតំរង់វាមក គឺខ្ញុំមិនដឹងជានិយាយថាម៉េចទេ គឺនៅក្នុងឃុំនេះគឺខ្ញុំអត់មានចេះខ្លាចទេ ហ៊ឺៗ...គឺថានៅក្នុងមួយឃុំនេះគឺថាខ្ញុំអត់ចេះខ្លាច គឺថាអត់មានខ្លាចអីទាំងអស់ គឺថាខ្ញុំតអីបានទាំងអស់ គឺថានៅក្នុងឃុំឲ្យតែគាដាច់លើកហើយគឺអាច គឺថាសុទ្ធតែវាមានបញ្ហាហើយ ទាល់តែមានបញ្ហាហើយទើបខ្ញុំលើក ដែលគេហៅថាជំទាស់នឹងការដឹកនាំមិនរីកចំរើន គឺចេះណាការអភិវឌ្ឍន៍ណា អីចឹងគឺថាខ្ញុំជំទាស់ចឹងហ្នឹង គឺថាឃើញគឺកែហ្នឹង គឺថាកែរដ្ឋាភិបាលទាំងស្រុង ។

កុសលៈ ចុះបើសិនថាឈ្លានពានដណ្ដើមយក អានេះវាគឺជារឿងធំ តែសួរថារដ្ឋាភបាលយើងអាចការពារបូរណៈភាពដែនដីយើងបានកំរិតណាដែរ បើតាមជំនឿរបស់លោកពូ បានតិចឬបានច្រើន?

ដាច់ៈ ហ៊ែ! ច្រើន ម៉េចបានថាច្រើន ពីព្រោះកាលនោះខ្ញុំយកអីវ៉ែអីវ៉ាន់ទៅប្រាសាទព្រះវិហារ ហើយគេឲ្យខ្ញុំនឹងដឹកនាំយកអាបន្ទែអាអី។ណា គឺយកទៅជូនដល់កងទ័ព ដូច្នេះគឺចាប់តាំងពីឆ្នាំ២០០៧មកម្ល៉េះណា គឺចាប់តាំងពីថ្ងៃទី១៥មក ដល់តែខ្ញុំទៅ។ គឺទៅដឹកយករបស់របរទៅឲ្យកងទ័ពនោះ ដល់អីចឹងគឺខ្ញុំឃើញថាកន្លែងទីតាំងនឹងការរៀបរយនោះគឺថារឹងពឹងណាស់ ហើយខ្ញុំមានជំនឿថាថៃមុននឹងយកបាននោះគឺល្អមើលហើយ អានេះគឺតាមដែលខ្ញុំមើលទេណា គឺថាល្អមើលហើយ គឺថាមិនងាយទេ ហើយវិធីសាស្ត្រយើងគឺថាវាខ្លាំងដែរណា គឺថាវិធីសាស្ត្រនៅខាងក្រៅ ។

កុសលៈ អីចឹងគឺថាមានជំនឿច្រើនថារដ្ឋាភិបាលអាចការពារបាន?

ដាច់ៈ បាទ! គឺថាខ្ញុំមានជំនឿច្រើន ។

កុសលៈ ប៉ុន្តែមានអ្នកខ្លះគឺគាត់ថានៅពេលដែលតាម៉ុកគាត់នៅ គឺគាត់អាចការពារបានច្រើនជាង?

ដាច់ៈ អត់ទេ គឺមិនអាចការពារបានទេ?

កុសលៈ គឺថាព្រំដែននៅខាងលើហ្នឹង គឺនៅខាងថៃឯណោះ?

ដាច់ៈ ណាំ! មិនដឹងជាព្រះអិននៅឯណាទេម៉េចនឹងការពារបាន ប៉ុន្តែពេលដែលតាម៉ុកគួងគឺនៅកន្លែងដដែលនេះ គឺមានទៅកន្លែងណា គឺកន្លែងដែលគេនៅត្រឹមណាគឺតាម៉ុកឲ្យគេនៅត្រឹមនឹងហើយ ។

កុសលៈ ពីព្រោះថានៅពេលដែលខ្ញុំលឺកន្លងមកគឺថាលឺផ្សេងវិញ?

ដាច់ៈ អត់ទេ!។ ។

កុសលៈ ពីមុនមកគឺខ្ញុំលឺថាព្រំដែនខ្មែរយើងមិនមែននៅកន្លែងយើងឥឡូវនោះទេ គឺនៅខាងមុខណោះ

ដាច់ៈ អត់ទេ។ គឺថាអត់មែនទេ កន្លែងដែលផ្ទះតាម៉ុក កន្លែងដែលត្រឹមរបងនោះគឺនៅតែរបងដដែល បាទ! អីចឹងគឺថាអត់មែនពិតទេ ហើយប្រាសាទព្រះវិហារដែលនៅកន្លែងកូនអូរនោះក៏នៅដដែល តែវាមិនសុខចិត្ត ហើយដែលវាឆ្លងមកគើបានជាវិវាទនោះ នៅពេលដែលវាឈ្លានពានមក ដែលឈ្លានពានមកយក៣០០ម៉ែត្រ ដែលយើងមិនឲ្យវានឹងហើយបានជាវិវាទនេះ ។

កុសលៈ បាទ! ខ្ញុំដឹងដែរ ។

ដាច់ៈ គឺនៅកន្លែងវាតត្រ័យនោះ កន្លែងសំបុកឃ្មុំនោះ អាកន្លែងកន្ទុកនោះ ។

កុសលៈ ចាំ! ខ្ញុំដូចជាអស់មានសំនួរអីហើយ តើលោកពូមានអីសម្រាប់ក្មេងជំនាន់ក្រោយដែលទេ តាមដែលបទពិសោធន៍របស់លោកពូ ដែលបានឆ្លងកាត់មក ដូចថាតើលោកពូមានអ្វីដែលជាវិប្បដិសារីដែលលោកពូបានឆ្លងកាត់មក ដែលថាលោកពូមិនដែលបានរៀនបានអី?

ដាច់ៈ ខ្ញុំគឺអត់មានដែលបានរៀនទេ ។

កុសលៈ តើលោកពូមានវិប្បដិសារីអ្វីដែលធំជាងគេបំផុតនោះ ដែលពូគិតថាលោកពូគួរតែបានធ្វើនោះ ពូមានដែលគិតថាតើលោកពូមានវិប្បដិសារីអីដែលឬទេ?

ដាច់ៈ មិនមានអីទេ គឺមិនមានអីផ្នែកពីនឹងតទៅទៀតទេ គឺថាមិនមានមតិអីច្រើន ប៉ុន្តែបើសិនជាបានសម្ភាសហើយនោះ គឺថាគោលបំណងរបស់ខ្ញុំគឺចង់ឲ្យជួយ ហើយជួយយ៉ាងម៉េច គឺថាជួយកន្លែងណាដែលខ្វះចន្លោះដល់រដ្ឋាភិបាលដែលមិនល្អ ដែលគេធ្វើអីដែលមិនល្អ អីចឹង ។

កុសលៈ តែលោកពូម៉ិញថាល្អទាំងអស់?

ដាច់ៈ អត់ទេ! គឺល្អ តែខ្វាចទៅខាងមុខគឺវាមិនល្អ អីចឹងគឺជួយ ជួយយ៉ាងម៉េច គឺថាយើងធ្វើម៉េចដើម្បីជួយកែធ្វើម៉េចឲ្យត្រូវ កុំឲ្យវាជ្រោះធ្លាយដូចនៅជំនាន់យើងមុនអញ្ចឹងណា តើមានអ្នកណាជាអ្នកដែលជួយកែយើង ។

កុសលៈ ខ្ញុំចង់សួរលោកពូត្រង់ គឺឆ្លើយឲ្យត្រង់ហ្នឹង តើវានៅខ្វះចន្លោះកន្លែងណាខ្លះដែរលោកពូ ជូនកាលសំនួរដែលសួរទៅគឺវានៅមានការខ្វះចន្លោះណាពូ ខ្ញុំចង់សួរលោកពូថារដ្ឋាភិបាលសព្វថ្ងៃនេះនៅខ្វះកន្លែងណាខ្លះ?

ដាច់ៈ ដែលជាចំនុចធំៗ! ។

កុសលៈ នឹងហើយ

ដាច់ៈ គឺខ្ញុំឃើញបន្តិច គឺខ្ញុំឃើញអញ្ចេះគឺនៅខាងផ្នែកការពារ គឺដូចថាផ្នែកខាងវ៉ាដ្យូដែលធ្លាប់តែនិយាយ គឺថាជារបបដែលពុករលួយ គឺខ្ញុំមានឃើញបញ្ហានេះគឺវាមិនសូវល្អទេ ហើយដែលគាថាអារបបពុករលួយនេះ គឺខ្ញុំមិនសូវជាដឹងវាពុករលួយអីខ្លះទេ គឺខ្ញុំមិនសូវជាដឹងអីទេ គឺលឺតែគេថាអីចឹង ។

កុសលៈ គឺមិនបាច់តែលឺទេ គឺគេឃើញគ្រប់តែគ្នា?

ដាច់ៈ អានឹងគឺអីចឹង អានឹងហើយដែលខ្ញុំឃើញនោះ ។

កុសលៈ គឺស្រែកពីក្រញ៉ូង គឺនៅតែឃើញក្រញ៉ូគេដឹកដដែលហ្នឹង?

ដាច់ៈ គឺស្រែកក្រញ៉ូងគឺក្រញ៉ូងដឹក ហើយត្រង់ស្រែកដីគឺលក់ដី គឺថាវាអីចឹងណា អីចឹងបានជាខ្ញុំថាវាមិនត្រូវនៅត្រង់ហ្នឹង ។

កុសលៈ អីចឹងឲ្យមានច្បាប់ឲ្យតឹងរឹងបន្តិច?

ដាច់៖ ឲ្យមានច្បាប់រឹតអាត្រង់នឹងឲ្យវាតឹងបន្តិច គឺឲ្យច្បាប់ជួយកែ គឺខ្ញុំឃើញពីបញ្ហានឹងមួយ ហើយបញ្ហាផ្សេងៗទៅទៀតនោះគឺខ្ញុំមិនមានទៅជាយល់ទាស់អីទេ តែចង់ឲ្យជួយពីលើបន្ថែមទៀតទៅលើការអភិវឌ្ឍ គឺអភិវឌ្ឍដល់ប្រជាពលរដ្ឋ ហើយសំខាន់គឺអ្នកដែលនៅចុងកាត់មាត់ញកតែដោយឡែកអ្នកដែលនៅក្នុងភូមិរបស់ខ្ញុំនេះ គឺវាបានខ្លះមកដែលហើយ តែក៏អត់ទាន់បានគ្រប់គ្រាន់ដែរទេ គឺមិនទាន់បានគ្រប់គ្រាន់ទេ គឺនៅទេ ។

កុសលៈ អីចឹងសំនួរចុងក្រោយគឺទាក់ទងទៅនឹងស្រុកអន្លង់វែងទាំងមូល ទោះបីជាមានអ្នកពិការម៉េចក៏ដោយគឺអត់មានអ្នកសុំទានតែម្តង?

ដាច់៖ អត់មាន ។

កុសលៈ ហេតុអី?

ដាច់៖ នេះក៏អត់មានទំលាប់ដូចអ្នកដែលនៅខាងក្នុង ។

កុសលៈ អត់ទំលាប់ម៉េចដែរពូ?

ដាច់៖ គឺអត់មានទំលាប់សុំ ឧទាហរណ៍ថាគេនៅឯក្នុងគឺគេ ឲ្យតែមានបុណ្យនៅត្រង់មានផ្សារនៅត្រង់ណា គឺចាប់ផ្តើមហើយមួក គឺមួយកាក់មួយសេនអីចឹងទៅណា គឺមានបត់ជើងក្រញោមក្រញោមអីចឹងទៅ នៅឯនេះគឺអត់ ។

កុសលៈ មិនទំលាប់នេះតាំងពីកាលណាមក?

ដាច់៖ ទំលាប់នេះគឺបើគិតទៅគឺតាំងពីជំនាន់ខ្មែរក្រហមមកម្ល៉េះ គឺពួកនេះដែលគេមកនៅមុនខ្ញុំនេះណា គេថាមិនដែលមានតែម្តង ដល់ពេលដែលខ្ញុំមកដល់ក៏មិនដែលឃើញ ដល់តែយើងធ្វើសមាហរន្នីកម្មមកដល់សព្វថ្ងៃក៏នៅតែមិនមាន គឺថាមួយរយមិនចង់មានមួយនោះណា ប៉ុន្តែខ្ញុំថាមានមួយទៅចុះ ។

កុសលៈ ប៉ុន្តែខ្ញុំផ្ទាល់គឺថាខ្ញុំមិនដែលឃើញ ធ្លាប់តែឃើញថាពួកគាត់ទៅធ្វើស្រែចំការអី អានឹងគឺធ្លាប់ឃើញមាន ។

ដាច់៖ អត់ទេ គឺថាមានដែរ តែមានមួយៗ តែមិនដឹងជាមកពីសៀមរាបឬក៏មកពីណាទេ ឃើញដើរដឹកឆ្កែរហើយឲ្យឆ្កែរដាក់លុយ ហើយដល់ពេលដែលឆ្កែរបានហើយក៏វាយកមកឲ្យម្ចាស់គឺខ្ញុំឃើញនៅនឹងផ្សារនេះម្តង តែប្រហែលជា២-៣ឆ្នាំហើយ តែស្រាប់ក៏បាត់ទៅ តែមិនដឹងជាមនុស្សនេះមកពីណាទេ មិនដឹងដែរ អីចឹងបើប្រៀបនៅក្នុងអន្លង់វែងគឺប្រហែលជាមិនឃើញទេ ។

កុសលៈ អានេះប៉េតាមដែលខ្ញុំដឹងមកគឺថាសេដ្ឋកិច្ចនេះគឺវាមានឬស្សីមានគល់ តើអានឹងវាទាក់ទងជាសេដ្ឋកិច្ចមួយនៅក្នុងមូលដ្ឋាន ពីព្រោះថាសេដ្ឋកិច្ចយើងមិនពឹងទៅលើកសិកម្មមិនអីចឹង

ហើយ មិនចាំបាច់និយាយទេនៅក្នុងអន្លង់វែងយើងនេះ គឺថានៅកន្លែងណាក៏មានចំការដំឡូងដែរ កន្លែងណាក៏មានស្រូវដែរ តើលោកពូយល់ថាសេដ្ឋកិច្ចមានឬស្សីមានគល់ ដែលរដ្ឋាភិបាលពីមុនថាវាជារឿងអាក្រក់នោះ

តើវានៅជាមូលដ្ឋានដែលថាវាល្អនៅក្នុងការអភិវឌ្ឍភូមិឃុំនៅយើងនេះសព្វថ្ងៃនេះដែលអត់?

ដាច់: នៅជំនាន់ខ្មែរក្រហមនោះ ។

កុសល: អត់ទេ គឺថាទំលាប់ដែលលោកពូនិយាយនោះណា ទំលាប់នោះគឺចង់និយាយថាសេដ្ឋកិច្ចមានឬស្សីមានគល់នោះណា តើវាសំខាន់ប៉ុនណានៅក្នុងការអភិវឌ្ឍន៍ភូមិស្រុក?

ដាច់: គឺខ្ញុំមើលឃើញថាយកទំលាប់ពីជំនាន់នោះមកគឺល្អណាស់ ជំនាន់នោះមកជំនាន់យើងមុនណាគឺថាមនុស្សអត់សូវចេះរិះគន់គ្នាទេ គឺរបបសព្វថ្ងៃនេះ គឺនិយាយតាំងពីសុំទានអីឡើងគឺអត់មានចេះរិះគន់គ្នាទេ ហើយម្យ៉ាងទៀតមនុស្សគឺច្រើនតែជាអ្នកចំណូលថ្មីមកនៅទីនេះ ស្រុកអន្លង់វែងមិនដឹងជាស្រុកទិសណាទេគឺថាម៉ាប្រទេសបើគិតទៅ ។

កុសល: មកគ្រប់?

ដាច់: គឺម៉ាប្រទេស គឺតាំងពីកំពត កំពង់ស្ពឺ អីគឺមកម៉ាប្រទេស ដើរសួរចុះ ដល់អីចឹងចូលមកគឺមនុស្សវានៅជាប់កំអែលពីនៅជំនាន់នោះទៅក៏វាចេះតែឡូឡេទៅ ដល់អីចឹងគឺថាមនុស្សវាអត់មានចះរិះគន់គ្នា តែមកដល់សព្វថ្ងៃនេះគឺថាវាចង់មានពុកត្រង់នេះបន្តិចនបន្តួច តែចាំមើលទេណា វាអត់ទាន់មានដូចពីណាអីគឺមិនដឹងទេ ពីព្រោះមិនទាន់ដឹងទេ ហើយខ្ញុំជាមនុស្សដែលមិនសូវដែលដើរទេ គឺនៅតែនឹងស្រុក គឺនៅតែអីចឹង សូម្បីតែគេថាគេទៅរកក្រញ៉ូងអីគឺខ្ញុំមិនដែលទៅទេ គឺថានៅតែផ្ទះ គឺថាខ្ញុំធ្វើតែស្រែទេ ហើយស្រែខ្ញុំនៅក្រោយផ្ទះ ។

កុសល: អីចឹងគឺខ្ញុំមានតែប៉ុណ្ណឹង គឺអត់មានអីច្រើនទេ អីចឹងខ្ញុំសូមអរគុណ ហើយអរគុណច្រើនដែលលោកពូបានជួយបំភ្លឺ ហើយបើឃើញថាមានការខ្វះខាតអីសូមជួយឲ្យយោបល់ផង ។

ដាច់: គឺឃើញថាមានអីចឹងឯង ហើយសូមឲ្យជួយតែប៉ុណ្ណឹងទេ ។

កុសល: ហើយបំណងដែលខ្ញុំមកនេះគឺមានបំណងចង់អោយ ដូចដែលខ្ញុំបានសួរលោកពូគឺដឹងហើយ គឺខ្ញុំមានបំណងចង់វាសះអាដំបៅនឹងណា គឺយើងក្លាយទៅជាប្រជាជនតែមួយ ហើយយើងចេះការពារព្រំដែនយើងឲ្យបានគង់វង្សនោះគឺចាត់ទុកថាជាការល្អហើយ ។

**ចប់**